ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តមណ្ឌលគិរី**
សំណុំរឿងរដ្ឋប្បវេណីលេខ ៖ ៥៥
ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១
សញ្ញាណនៃរឿងក្តី ៖ បណ្តឹងលែងលះ
សាលក្រមរដ្ឋប្បវេណី
លេខ: ០៣ "គ១/២២".
ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២២

# សាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តមណ្ឌលគិរី

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់
នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១

**ចៅក្រមជំនុំជម្រះ**

លោកស្រី [redacted] ចៅក្រមសាលាដំបូងខេត្តមណ្ឌលគិរី

**ក្រឡាបញ្ជី**

លោកស្រី [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តមណ្ឌលគិរី

**ដើមចោទ**

ឈ្មោះ [redacted]ចាន់ថន ភេទ ស្រី អាយុ ៤៥ឆ្នាំ ជនជាតិខ្មែរ មុខរបរលក់ដូរ មានទីលំនៅបច្ចុប្បន្នភូមិ [redacted]។

**អ្នកតំណាងដោយអាណត្តិ**

លោកមេធាវី [redacted]អត្តលេខ ២៣២៧ T នៅការិយាល័យ ក្រុមមេធាវី [redacted]។

**ចុងចម្លើយ**

ឈ្មោះ [redacted] ចន្ថា ភេទប្រុស អាយុ៥៥ឆ្នាំ ជនជាតិខ្មែរ មុខរបរអ្នកសារព័ត៌មាន មានទីលំនៅបច្ចុប្បន្ន [redacted]។

**អ្នកតំណាងដោយអាណត្តិ** "គ្មាន ៕

**អង្គហេតុ និង ចំណុចវិវាទ**

**១. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ ÷**

១. លែងលះពីចុងចម្លើយឈ្មោះ[redacted]ចន្ថា។

២. សុំសិទ្ធិអំណាចមេបាលើការគ្រប់គ្រងកូនចំនួន០១នាក់ឈ្មោះ [redacted]សុរចនា ភេទស្រី កើតថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៧។

៣. បំណុល៖ ជំពាក់ធនាគារអេស៊ីលីដាចំនួន ៨០.០០០ (ប្រាំបីម៉ឺន) ដុល្លារអាមេរិក និង កម្ចីប្រាក់ឯក



Scanned with CamScanner

ជនចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ដើមចោទទទួលបន្ទុកវ៉ាប់រងសងតែម្នាក់ឯង លុះត្រាតែភាគីចុងចម្លើយព្រមប្រគល់ទ្រព្យសម្បត្តិរួមឱ្យដើមចោទ។

៤. ទាមទារបែងចែកទ្រព្យសម្បត្តិរួមដូចខាងក្រោម៖

- ដីចំការទំហំ ៩០ម៉ែត្រ គុណនឹង ២៥០ ម៉ែត្រ ស្ថិតនៅភូមិពូត្រុំ សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី។

-ដីលំនៅឋានទំហំ ០៧ ម៉ែត្រ គុណនឹង ១២ ម៉ែត្រ ស្ថិតនៅភូមិកណ្តាល សង្កាត់ស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី។

-រថយន្តម៉ាក HYUNDAI LIBERO ពាក់ស្លាកលេខ 2AS-0687 ពណ៌ស ផលិតនៅឆ្នាំ២០០២

- ដីនិងផ្ទះទំហំ ៥ ម៉ែត្រ គុណនឹង ១៩ ម៉ែត្រ ស្ថិតនៅភូមិអូរ១ សង្កាត់អូរឬស្សី ក្រុងក្រចេះ ខេត្តក្រចេះ និង រថយន្តម៉ាកTACOMA ផលិតនៅឆ្នាំ២០០៩ ពណ៌ទឹកមាស ចំនួន០១គ្រឿង ប្រគល់ឱ្យទៅចុងចម្លើយជាអ្នកមានសិទ្ធិគ្រប់គ្រង និងចាត់ចែង។

៥. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

## ២. អំពីដំណើររឿងក្តី និងចំណុចវិវាទ

### ២.១. ការសង្ខេបអំពីរឿងក្តី

ដើមចោទឈ្មោះ [redacted]ចាន់ថន និងចុងចម្លើយឈ្មោះ [redacted] បានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីជាមួយគ្នាតាំងពីឆ្នាំ ១៩៩៣ ប៉ុន្តែបានចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នានៅឆ្នាំ ២០១៨ ។ ដើមចោទដាក់ពាក្យបណ្តឹងលែងលះពីចុងចម្លើយដោយមូលហេតុថាប៉ុន្មានឆ្នាំចុងក្រោយ ចុងចម្លើយបានទៅធ្វើការនិងរស់នៅខេត្តក្រចេះ ហើយមិនសូវត្រលប់មកផ្ទះរស់នៅជុំមើលថែប្រពន្ធកូន និងបានទាមទារយកសិទ្ធិអំណាចមេបាលើកូនស្រីជាអនីតិជនម្នាក់ ទាមទារបែងចែកបំណុល បែងចែកទ្រព្យសម្បត្តិរួមជាមួយចុងចម្លើយ។

### ២.២. អង្គហេតុដែលមានវិវាទ

គ្មាន

### ២.៣. ចំណុចវិវាទ

គ្មាន

## សំអាងហេតុ

ផ្អែកតាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាងនានាដែលមានក្នុងសំណុំរឿងយល់ឃើញថា៖

១. តាមសំបុត្រអាពាហ៍ពិពាហ៍លេខ ៣៩ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៨ នៃសៀវភៅអាពាហ៍ពិពាហ៍លេខ ១ ឆ្នាំ២០១៨ បញ្ជាក់បានថាដើមចោទឈ្មោះ [redacted] ចាន់ថន និង ចុងចម្លើយឈ្មោះ [redacted] ចន្ថា ជាប្តីប្រពន្ធនិងគ្នា ដែលមានអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ។



Scanned with CamScanner

២. ដើមចោទបានទាមទារលែងលះពីចុងចម្លើយ ដោយអះអាងលើមូលហេតុថាប៉ុន្មានឆ្នាំចុងក្រោយចុងចម្លើយបានទៅធ្វើការនិងរស់នៅឯខេត្តក្រចេះ ហើយមិនសូវត្រលប់មកផ្ទះមើលថែប្រពន្ធកូន ដោយទុកឲ្យដើមចោទរស់នៅមើលថែកូនៗតែម្នាក់ឯង ។ ចុងចម្លើយមិនបានបដិសេធអំពីការអះអាងរបស់ដើមចោទត្រង់ចំណុចនេះ ហើយក៏មិនបានបដិសេធចំពោះការទាមទារលែងលះពីដើមចោទផងដែរ។

យល់ឃើញថា តាមរយៈការអះអាងរបស់ភាគីដើមចោទនិងចុងចម្លើយបង្ហាញបានថា ភាគីទាំងសងខាងមិនមានឆន្ទៈក្នុងការបន្តចំណងអាពាហ៍ពិពាហ៍ ហើយទំនាក់ទំនងជាប្ដីប្រពន្ធរវាងដើមចោទ និងចុងចម្លើយអស់មនោសញ្ចេតនារវាងគ្នា ដែលមិនអាចធ្វើបដិទានបាន។ ដូច្នេះការទាមទាររបស់ដើមចោទ គឺមានមូលហេតុដូចមានចែងនៅក្នុងមាត្រា ៩៧៨ កថាខណ្ឌ ១ ចំណុច ង នៃក្រមរដ្ឋប្បវេណី។

៣. តាមសំបុត្រកំណើតលេខ ២៣ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៣ នៃសៀវភៅបញ្ជាក់កំណើតលេខ០១ ឆ្នាំ២០១៣ ឃើញថា ឈ្មោះ [redacted] សុរចនា កើតថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៧ ហើយមានឪពុកឈ្មោះ [redacted] ចន្ថា និងម្ដាយឈ្មោះ [redacted] ចាន់ថន ។ តាមរយៈនេះអាចបង្ហាញថាឈ្មោះ [redacted] សុរចនា ជាអនីតិជន និងត្រូវកូនរបស់ដើមចោទ និងចុងចម្លើយ។

ដើមចោទជាម្ដាយបានទាមទារយកអំណាចមេបាលើកូនស្រីឈ្មោះ [redacted] សុរចនា ហើយមិនទាមទារយកសោហ៊ុយចាំបាច់ដើម្បីចិញ្ចឹមកូនពីចុងចម្លើយ។ ចុងចម្លើយមិនបានបដិសេធអំពីការទាមទារនេះ។

យល់ឃើញថា បច្ចុប្បន្នឈ្មោះ [redacted] សុរចនា ពីដើមមករស់នៅជាមួយដើមចោទជាម្ដាយ ហើយជាសិស្សដែលកំពុងរៀននៅសាលាស្ថិតនៅខេត្តមណ្ឌលគិរី ចំណែកចុងចម្លើយជាឪពុកបច្ចុប្បន្នរស់នៅឯខេត្តក្រចេះ ហេតុនេះ ការទាមទាររបស់ដើមចោទជាអ្នកមានអំណាចមេបាលើកូន គឺមានហេតុផលសមរម្យ និងគប្បីយកដើមចោទជាអ្នកមានអំណាចមេបា។

៤. ដើមចោទបានទាមទារឲ្យតុលាការធ្វើការសម្រេចអំពីបំណុលដែលដើមចោទ និងចុងចម្លើយបានខ្ចីពីធនាគារអេស៊ីលីដាចំនួន ៨ (ប្រាំបី) ម៉ឺនដុល្លារអាមេរិក និង កម្ចីពីឯកជនចំនួន ២ (ពីរ) ម៉ឺនដុល្លារអាមេរិក។ ចំពោះករណីដែលដើមចោទ និងចុងចម្លើយ ជាប្ដីប្រពន្ធបានទៅខ្ចីប្រាក់រួមគ្នា ពោលបង្កើតកាតព្វកិច្ចរួមគ្នា នោះភាគីទាំងពីរត្រូវទទួលបន្ទុកដោយសាមគ្គីភាព ហើយជាទ្រព្យអកម្ម។

យល់ឃើញថា ការទាមទារនេះ គឺជាការបែងចែកទ្រព្យអកម្ម ដែលពុំមែនជាកម្មវត្ថុនៃការបែងចែកក្នុងរឿងក្ដីលែងលះឡើយ ដែលគប្បីលើកចោលការទាមទារ ផ្អែកតាមមាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណី។

៥. ការបែងចែកទ្រព្យសម្បត្តិរួមរវាងដើមចោទ និង ចុងចម្លើយ៖

៥.១. ដើមចោទ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីជាមួយគ្នាតាំងពីឆ្នាំ១៩៩៣ ក៏ប៉ុន្តែទើបតែបានចុះបញ្ជីអាពាហ៍ពិពាហ៍ជាមួយគ្នានៅឆ្នាំ ២០១៨ ។ ហើយទ្រព្យសម្បត្តិដែលដើមចោទបានទាមទារឲ្យបែងចែកឃើញថាមានទ្រព្យមួយចំនួនមានមុនឆ្នាំ ២០១៨ ប៉ុន្តែភាគីទាំងសងខាងក៏បានទទួលស្គាល់ថាជាទ្រព្យដែលដើមចោទ និង ចុងចម្លើយបានទទួលរួមគ្នា ហេតុនេះទ្រព្យសម្បត្តិដែលដើមចោទទាមទារឲ្យធ្វើការបែងចែកត្រូវកំណត់ថាជាទ្រព្យសម្បត្តិរួមរវាងដើមចោទនិងចុងចម្លើយ។



Scanned with CamScanner

៥.២. ដើមចោទទាមទារបែងចែក ដីចំការមួយកន្លែងដែលមានទំហំ **៩០ម៉ែត្រ គុណនឹង ២៥០ម៉ែត្រ** ស្ថិតនៅភូមិពូត្រុំ សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី មកជាកម្មសិទ្ធិរបស់ខ្លួនហើយយកទៅលក់បានប្រាក់ បែងចែកឱ្យទៅចុងចម្លើយចំនួន **៥ ម៉ឺនដុល្លារអាមេរិក** ។

ចុងចម្លើយមិនបានបដិសេធចំពោះការទាមទាររបស់ដើមចោទ ។ ហេតុនេះ ចុងចម្លើយបានទទួលស្គាល់ការទាមទាររបស់ដើមចោទត្រង់ចំណុចនេះ។

៥.៣. ដីលំនៅឋានមួយកន្លែងមានទំហំ **០៧ម៉ែត្រ គុណនឹង ១២ម៉ែត្រ** ស្ថិតនៅភូមិកណ្តាល សង្កាត់ស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ដើមចោទ និងចុងចម្លើយបានព្រមព្រៀងគ្នាធ្វើការផ្ទេរឱ្យទៅជាកម្មសិទ្ធិអវិភាគរបស់កូនឈ្មោះ [redacted] **ចាន់ថេង** និង កូនឈ្មោះ [redacted] **វិចិត្រ**។

យល់ឃើញថា ការព្រមព្រៀងរវាងដើមចោទ និង ចុងចម្លើយក្នុងការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដែលជាទ្រព្យសម្បត្តិរួមឱ្យទៅកូន មិនមែនជាការបែងចែកទ្រព្យសម្បត្តិរួមនោះទេ ប៉ុន្តែគឺជាការចាត់ចែងទ្រព្យរួមតាមការព្រមព្រៀង ដែលដើមចោទនិងចុងចម្លើយអាចធ្វើនីតិវិធីនៃការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុបាននៅអាជ្ញាធរមានសមត្ថកិច្ច ស្របតាមបញ្ញត្តិមាត្រា **៩៧៦** នៃក្រមរដ្ឋប្បវេណី ដោយពុំចាំបាច់មានសេចក្តីសម្រេចរបស់តុលាការនោះឡើយ។ ហេតុនេះ ការទារទាមទារត្រង់ចំណុចនេះត្រូវលើកចោល។

៥.៤. ដើមចោទទាមទារយករថយន្តម៉ាក HYUNDAI LIBERO ពាក់ស្លាកលេខ 2AS-0687 ពណ៌ស ស៊េរីឆ្នាំ២០០២ ជាកម្មិសិទ្ធិរបស់ខ្លួន។

ចុងចម្លើយមិនបានបដិសេធចំពោះការទាមទារនេះ។ ហេតុនេះចុងចម្លើយទទួលស្គាល់ការទាមទាររបស់ដើមចោទត្រង់ចំណុចនេះ។

៥.៥. ដី និងផ្ទះទំហំ ៥ម៉ែត្រ គុណនឹង ១៩ម៉ែត្រ ស្ថិតនៅភូមិអូរ១ សង្កាត់អូរឫស្សី ក្រុងក្រចេះ ចុងចម្លើយទាមទារយកជាកម្មសិទ្ធិរបស់ខ្លួន។ ដើមចោទ មិនបានបដិសេធចំពោះការទាមទាររបស់ចុងចម្លើយ។

៥.៦. រថយន្តម៉ាក TACOMA ពណ៌មាស ស៊េរីឆ្នាំ២០០៩ ពាក់ស្លាកលេខភ្នំពេញ 2U-5060 ចុងចម្លើយទាមទារយកជាកម្មសិទ្ធិរបស់ខ្លួន។ ដើមចោទ មិនបានបដិសេធចំពោះការទាមទាររបស់ចុងចម្លើយ។

៦. ប្រាក់ប្រដាប់ក្តី ត្រូវពិចារណាតាមបញ្ញត្តិមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## សេចក្តីសម្រេចបញ្ចប់

១- លែងលះដើមចោទឈ្មោះ [redacted]ាន់ថន និងចុងចម្លើយឈ្មោះ [redacted] ចន្ថា ។

២- កំណត់ឱ្យដើមចោទឈ្មោ[redacted] **ចាន់ថន** ជាអ្នកមានអំណាចមេបាលើកូនរវាងដើមចោទ និងចុងចម្លើយដែលមានឈ្មោះ[redacted]**សុរចនា** ភេទស្រី កើតថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៧ ។

៣- លើកចោលការទាមទារចំណុចទី៣។

៤- បែងចែកទ្រព្យសម្បត្តិរួមរវាងដើមចោទ និង ចុងចម្លើយ ដូចខាងក្រោម៖

ក. ដីចំការមានក្បាលដីលេខ ខ៤៣៦ ទំហំ ៩០ ម៉ែត្រ គុណនឹង ២៥០ម៉ែត្រ ស្ថិតនៅភូមិពូត្រុំ សង្កាត់ រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ត្រូវជាកម្មសិទ្ធិរបស់ដើមចោទឈ្មោះ[redacted] **ចាន់ថន**។



Scanned with CamScanner

បង្គាប់ឱ្យដើមចោទឈ្មោះ [redacted]ចាន់ថន លក់ដីខាងលើនេះ ហើយយកប្រាក់ចំនួន ៥ (ប្រាំ) ម៉ឺនដុល្លារអាមេរិក ឱ្យទៅចុងចម្លើយឈ្មោះ [redacted]ចន្ថា។

ខ. រថយន្តម៉ាក HYUNDAI LIBERO ពាក់ស្លាកលេខ 2AS-0687 ពណ៌ស ជាកម្មសិទ្ធិរបស់ដើមចោទឈ្មោះ [redacted] ចាន់ថន។

គ. ដី និងផ្ទះទំហំ ៥ ម៉ែត្រ គុណនឹង ១៩ម៉ែត្រ ស្ថិតនៅភូមិអូរ១ សង្កាត់អូរឬស្សី ក្រុងក្រចេះ ខេត្តក្រចេះ ដែលមានកិច្ចសន្យាលក់ទិញពីឈ្មោះ [redacted]ណាន និងឈ្មោះ [redacted] ស្រីនាថ ជាកម្មសិទ្ធិចុងចម្លើយឈ្មោះ [redacted] ចន្ថា។

ឃ. រថយន្តម៉ាក TACOMA ពណ៌ទឹកមាស ពាក់ស្លាកលេខភ្នំពេញ 2U5060 ជាកម្មសិទ្ធិរបស់ចុងចម្លើយឈ្មោះ [redacted] ចន្ថា។

៥- ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

សាលក្រមនេះ បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១ និងប្រកាសជាអសាធារណៈនៅថ្ងៃទី១១ ខែមករា ឆ្នាំ២០២២ ចំពោះមុខដើមចោទ និងចុងចម្លើយ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា [redacted]

---

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃ អង្គារ ៩កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅមណ្ឌលគិរី ថ្ងៃទី១១ ខែមករា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]